ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃការអញ្ជើញចូលរួមរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងសម័យប្រជុំលើកទី៧៣របស់មហាសន្និបាតអង្គការសហប្រជាជាតិ

*********

នៅថ្ងៃទី ២៨ ខែកញ្ញាឆ្នាំ ២០១៨ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៧៣ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។

ក្នុងនាមជាប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី ៦ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងបទអន្តរាគមន៍នៅចំពោះមុខអង្គមហាសន្និបាត ដោយបានរំលេចពីមុខមាត់ថ្មីរបស់កម្ពុជា នៅក្នុងកិច្ចដំណើរការប្រជាធិបតេយ្យប្រកបដោយស្ថិរភាព និងសមិទ្ធផលសេដ្ឋកិច្ចសង្គមគួរឲ្យកត់សំគាល់ បន្ទាប់ពីទទួលបានសន្តិភាព និងស្ថិរភាពពេញលេញនៅទូទាំងប្រទេស។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនស្របតាម "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា" ដែលនឹងត្រូវអនុម័តក្នុងពេលដ៏ឆាប់ខាងមុខ។

ទាក់ទងនឹងកិច្ចការអន្តរជាតិ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកឡើងពីការព្រួយបារម្ភចំពោះការគំរាមកំហែងនៃនិន្នាការឯកតោភាគីនិយម ដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធពហុភាគីនិយម និងបង្អាក់កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីឈានទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមសន្តិសុខរួមផ្សេងៗទៀត។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអំពាវនាវឱ្យគោរពធម្មនុញ្ញអ.ស.ប. និងជៀសវាងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា ក្រោមលេសការពារសិទ្ធិនយោបាយ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកពីករណីជាក់ស្តែងរបស់កម្ពុជាដែលមជ្ឈដ្ឋានខាងក្រៅមួយចំនួននៅតែចិញ្ចឹមមហិច្ឆតារបស់ខ្លួនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយធ្វើជាមើលមិនឃើញនូវគុណភាព និងសុចរិតភាពនៃដំណើរការបោះឆ្នោតរបស់កម្ពុជា តាមរយៈការចេញសេចក្តីថ្លែងការណ៍នានាប្រឆាំងនឹង ឬធ្វើការវាយប្រហារលើលទ្ធផលនៃការបោះឆ្នោត។ ទង្វើបែបនេះគឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរចំពោះឆន្ទៈរបស់ប្រជាជនកម្ពុជា។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh

ទាក់ទងនឹងការទប់ស្កាត់ជម្លោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានរំលេចអំពីការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងការគាំទ្រដល់ប្រតិបត្តិការថែរក្សាសន្តិភាពអ.ស.ប. នៅទូទាំងពិភពលោក ទោះបីជាត្រូវប្រឈមនឹងហានិភ័យគ្រោះថ្នាក់ដល់អាយុជីវិតក៏ដោយ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបជាមួយឯកឧត្តម **អង់តូនីញ៉ូ ហ្គូតេរ៉េស** អគ្គលេខាធិការអ.ស.ប.ផងដែរ។ ឯកឧត្តមអគ្គលេខាធិការបានកោតសរសើរចំពោះសមិទ្ធផលរបស់កម្ពុជា ក្នុងការសម្រេចបានសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងតួនាទីយ៉ាងសកម្មក្នុងការគាំទ្រដល់ប្រព័ន្ធអ.ស.ប.។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីការបន្តជួយគាំទ្រដល់បេសកកម្មរក្សាសន្តិភាព និងបានស្នើឲ្យមានការបន្តនីតិវិធីដែលមានបច្ចុប្បន្ន ទាក់ទងនឹងការចូលវិភាគទានចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ឯកឧត្តមអគ្គលេខាធិការ ចំពោះការគាំទ្ររបស់លោកចំពោះប្រទេសកម្ពុជា និងបានគូសបញ្ជាក់ថា កម្ពុជាត្រៀមខ្លួនរួចជាស្រេចដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការជាមួយអ.ស.ប. ជាពិសេសនៅពេលដែលកម្ពុជាទទួលតួនាទីពីរក្នុងឋានៈជាអនុប្រធាននៃមហាសន្និបាតអ.ស.ប លើកទី ៧៣ និងជាសមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អ.ស.ប. (ECOSOC) សម្រាប់ឆ្នាំ ២០១៩។ ដើម្បីបង្ហាញពីឆន្ទៈនយោបាយដ៏រឹងមាំ និងការប្តេជ្ញាចិត្តប្រកបដោយសង្គតិភាពរបស់កម្ពុជា ក្នុងការលើកស្ទួយសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជម្រាបជូន ឯកឧត្តមអគ្គលេខាធិការ ពីការយល់ព្រមពន្យារអនុស្សរណៈយោគយល់គ្នាដែលនឹងត្រូវអស់សុពលភាពនៅចុងឆ្នាំនេះ ដើម្បីអនុញ្ញាតឲ្យការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអ.ស.ប. បន្តវត្តមានរបស់ខ្លួននៅកម្ពុជាពីរឆ្នាំបន្តទៀត។

ក្នុងឱកាសនេះដែរ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានជួបទ្វេភាគីជាមួយឯកឧត្តម **ខាត់ហ្កា ប្រាសាទ ស្សាម៉ា អូលី** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ និងឯកឧត្តម **បូយកូ បូរីសូវ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប៊ុលហ្គារី ដែលឯកឧត្តមទាំងពីរបានអបអរសាទរសម្តេចតេជោនាយករដ្ឋមន្ត្រីបានជាប់ឆ្នោតជាថ្មីម្តងទៀត។ ភាគីទាំងសងខាងបានផ្លាស់ប្តូរយោបល់ស្តីពីការជំរុញមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណនេប៉ាល់ ដែលបានបញ្ជូនអ្នកសង្កេតការណ៍ចូលរួមពិនិត្យមើលដំណើរការបោះឆ្នោតសកលនីតិកាលទី ៦ របស់កម្ពុជា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់អំពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណបក្សនយោបាយនិយមកណ្តាល (CDI) ទន្ទឹមគ្នានឹងការបំពេញទស្សនកិច្ចនៅប្រទេសនេប៉ាល់ នៅចុងខែវិច្ឆិកា ២០១៨ ខាងមុខ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតួនាទីរបស់ប្រទេសប៊ុលហ្គារី កាលពីអតីតកាលដែលបានជួយឧបត្ថម្ភដល់ប្រទេសកម្ពុជា ក្រោយការរំដោះចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងចូលរួមចំណែកថែរក្សាសន្តិភាពនៅកម្ពុជា ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជំរាបអំពីការរៀបចំបើកស្ថានឯកអគ្គរាជទូតកម្ពុជា នៅទីក្រុង

សូហ្វីយ៉ា ជាថ្មីឡើងវិញ នៅឆ្នាំ២០១៩ ខាងមុខ និងអំពីគោលបំណងនៃការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប នៅប្រទេសកម្ពុជានាឆ្នាំ២០២០។ ឯកឧត្តមនាយករដ្ឋមន្ត្រី ប៊ុលហ្គារី បានស្វាគមន៍ការបើកស្ថានទូតឡើងវិញ និងបានឯកភាពចំពោះសំណើធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប នៅប្រទេសកម្ពុជា។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបប្រាស្រ័យទាក់ទងជាមួយនឹងវិស័យឯកជនផងដែរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបជាមួយនឹងតំណាងក្រុមហ៊ុន General Electric ( GE ) Global Growth និងបានធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយមូលនិធិ GE Foundation ស្តីពីការអនុវត្តការវះកាត់ប្រកបដោយសុវត្ថិភាពឆ្នាំ ២០២០។ **សម្តេចតេជោ** ក៏បានជួបជាមួយលោក **អាឡិចសាន់ឌ័រ ហ្វែលម៉ាន** ប្រធានក្រុមប្រឹក្សាប្រតិបត្តិនៃក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ានផងដែរ ដើម្បីពិភាក្សាពីការជំរុញកិច្ចសហប្រតិបត្តិការធុរកិច្ច។

ជាមួយនឹងការចូលរួមអមដំណើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអ.ស.ប. ដែលជាតួនាទីប្រវត្តិសាស្រ្តរបស់កម្ពុជា ក្នុងឋានៈជាអនុប្រធាននៃមហាសន្និបាតអ.ស.ប. លើកទី ៧៣ និងបានជួបពិភាក្សាទ្វេភាគីជាមួយបណ្តាប្រទេសនានា ដែលមានខ្លឹមសារដូចខាងក្រោម៖

- ឯកឧត្តម **អ៊ីវីកា ដាស៊ីក** ឧបនាយករដ្ឋមន្ត្រីទី ១ និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសែប៊ី បានសម្តែងការអបអរសាទរចំពោះការបោះឆ្នោតប្រកបដោយជោគជ័យរបស់កម្ពុជា ហើយបានសន្យាបន្តគាំទ្រប្រទេសកម្ពុជាលើក្របខ័ណ្ឌអន្តរជាតិ។ ភាគីទាំងពីរបានកត់សម្គាល់ពីកិច្ចពិគ្រោះយោបល់នយោបាយលើកទី ២ នាពេលខាងមុខនេះរវាងក្រសួងការបរទេសទាំងពីរ នៅថ្ងៃទី ២០ ខែវិច្ឆិកាឆ្នាំ ២០១៨ នៅរាជធានីភ្នំពេញ ដែលមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើន។
- ជំនួបជាមួយសមាជិកព្រឹទ្ធសភាលោកជំទាវ **ម៉ារីស ផេន** រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី ឯកឧត្តម **ស្វេន មីកស៊ើ** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋអេស្តូនី និងឯកឧត្តម **ម៉ាក ហ្វៀល** រដ្ឋលេខាធិការទទួលបន្ទុកកិច្ចការអាស៊ី និងប៉ាស៊ីហ្វិករបស់ចក្រភពអង់គ្លេស បានពិភាក្សាផ្លាស់ប្តូរយោបល់ដើម្បីស្វែងរកកាលានុវត្តភាពបន្ថែមទៀត ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីដើម្បីផលប្រយោជន៍ទៅវិញទៅមក។
- ឯកឧត្តម **ភីធើ ហ្ស៊ីចាតូ** រដ្ឋមន្ត្រីការបរទេសហុងគ្រី បានសម្តែងនូវការអបអរសាទរចំពោះជោគជ័យនៃការបោះឆ្នោតថ្មីៗនេះនៅកម្ពុជា និងបានសម្តែងការត្រៀមខ្លួនរួចជាស្រេចដើម្បីស្វាគមន៍ដំណើរទស្សនកិច្ចជាផ្លូវការរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី នៅប៊ុយដាប៉េស នៅខែធ្នូ ឆ្នាំ២០១៨ ។ ឯកឧត្តមបានមានប្រសាសន៍ថា ប្រទេសហុងគ្រីត្រៀមខ្លួនដើម្បីបង្កើន

ចំនួនអាហារូបករណ៍ដល់និស្សិតកម្ពុជា និងស្វាគមន៍សំណើកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានការទូតនៃក្រសួងការបរទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្វាគមន៍ការបើកការិយាល័យតំណាងការទូតរបស់ប្រទេសហុងគ្រីនៅក្នុងទីក្រុងភ្នំពេញនៅចុងឆ្នាំនេះ។

- ក្នុងជំនួបជាមួយឯកឧត្តម **ហ្សូរ៉ាប់ ម៉ូណាតសាកាយ៉ាន** រដ្ឋមន្ត្រីការបរទេសនៃប្រទេសអាមេនី ភាគីទាំងពីរបានបញ្ជាក់ពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការអភិវឌ្ឍបន្ថែមទៀតនូវកិច្ចសហ-ប្រតិបត្តិការជាក់ស្តែងក្នុងវិស័យកសិ-ពាណិជ្ជកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និងការអប់រំ។ រដ្ឋមន្ត្រីទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ ដែលមានគោលបំណងជំរុញបន្ថែមការប្រាស្រ័យទាក់ទង និងបង្កើនកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាលើវិស័យជាច្រើនផ្សេងទៀត។ ឯកឧត្តម **ហ្សូរ៉ាប់ ម៉ូណាតសាកាយ៉ាន** បានសម្តែងនូវការគាំទ្រចំពោះការចូលរួមរបស់កម្ពុជាជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ុប (EAEU) ជាពិសេសការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និង EAEU។ អាមេនីទន្ទឹងរង់ចាំស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់កម្ពុជា ក្នុងឱកាសកិច្ចប្រជុំកំពូលនៃអង្គការហ្វ្រង់កូហ្វូនី នៅខែតុលា ឆ្នាំ២០១៨ នៅក្នុងប្រទេសអាមេនី៕

ថ្ងៃព្រហស្បតិ៍ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១៨